# កិច្ចអន្តរាគមន៍ព្រះនារាយណ៍ក្នុងចម្បាំងខ្មែរ-ចាម្ប នៅចម្លាក់ប្រាសាទបាយ័ន្ត

ប្រាសាទបាយ័នសាងសង់នៅស.វទី១២ ក្នុងរាជ្យព្រះបាទជ័យវម៌្មនទី៧។ ការសិក្សាបកស្រាយចម្លាក់តាមថែវនៅប្រាសាទបាយ័នមានជាហូរហែរហូតមកដល់បច្ចុប្បន្ន។ កាលណាយើងទៅប្រាសាទបាយ័ន មុននឹងឡើងដល់ក្ដីកណ្ដាលប្រាសាទ គេត្រូវឆ្លងកាត់ថែវមានចម្លាក់២សិន។ ដូចយើងដឹងទូទៅ ថែវទី១និយាយពីសង្គ្រាម ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងបង្ហាញទិដ្ឋភាពទូទៅនៃជីវភាពមនុស្ស។[1] ដល់ថែវទី២និយាយច្រើនទាក់ទងនឹងកិច្ចពិធីសាសនា និងអានុភាពរបស់ទេពសំខាន់ៗ។ ថែវនេះទាក់ចិត្តអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិមិនតិចឡើយ។

គេដឹងជាទូទៅថា ថែវខាងលិចនិយាយជាពិសេសអំពីភាពអស្ចារ្យនានារបស់ព្រះនារាយណ៍មានដូចជា រឿងកូរសមុទ្រទឹកដោះ និងការប្រកួតធ្នូជាដើម។[2] អត្ថបទនេះនឹងយកចម្លាក់នៅថែវខាងលិចជ្រុងខាងត្បូងមកពិនិត្យបន្ថែម ដោយយោងទៅលើការស្រាវជ្រាវមុនៗ និងយកព័ត៌មានពីសិលាចារឹកខ្លះៗដែលចារក្នុងសម័យកាលដូចគ្នាមកពិចារណា។

ផ្ទាំងចម្លាក់នេះបង្ហាញពីកងទ័ពខ្មែរធ្វើដំណើរពីឆ្វេងទៅស្ដាំឆ្ពោះទៅមុខដោយមានទ័ពចាម្បមួយក្រុមនៅជួរមុខ ឯក្បួនទ័ពចាម្បដើរពីខាងស្ដាំមកខាងឆ្វេង (រូបលេខ១)។ នៅកណ្ដាលចំណោមពលទ័ពទាំង២គឺ រូបព្រះនារាយណ៍គង់លើគ្រុឌសំកាងស្វាប ហើយបែរព្រះភក្ត្រទល់ទ័ពចាម្បក្នុងកាយវិការត្រៀមប្រយុទ្ធ។ នៅខាងក្រោយព្រះនារាយណ៍មានទ័ពខ្មែរលាយនឹងទ័ពចាម្បសម្រុកទៅមុខ (រូបលេខ២)។[3] ចំណែកមេទ័ពចាម្បដឹកនាំមុខគេមកតទល់នឹងទ័ពខ្មែរ កាលបើជិតដល់ព្រះនារាយណ៍ក៏ស្រាប់តែលើកដៃបង្គំប្រណម

---

[1] អ៊ឹម សុខរិទ្ធី ១៩៩៥, ហ៊្វូន សាវង ២០១១។

[2] ស៊ីយ៉ុន សុភារីទ្ធ ២០០៧។

[3] ក្នុងរាជ្យព្រះបាទជ័យវម៌្មនទី៧មានទ័ពចាម្បដែលចំណុះទ័ពខ្មែរចូលរួមប្រយុទ្ធទ័ពចាម្ប )Vickery 2005: 70-71)។

អត្ថបទដោយៈ អ៊ូ គង្គា

គោរពព្រះចេស្តាព្រះនារាយណ៍ដែលកំពុងគង់លើគ្រុឌសំកាំងនៅស្ទាបខាងមុខទៅវិញ (រូបលេខ២៣)។



រូបលេខ២១



រូបលេខ២២



រូបលេខ២៣

ករណីខាងលើនេះ ដាំ ទិត្យាវ័ណ្យ ពន្យល់ថា ចម្លាក់នេះបង្ហាញពីទ័ពខ្មែរចេញច្បាំងជាមួយចាម្បដែលមានកិច្ច «អន្តរាគមន៍» ពីព្រះនារាយណ៍ ហើយថែមទាំងបាននិយាយច្បាស់ៗថា អ្នកដែលគង់លើខ្នងដំរីនាំមុខគេនោះ គឺជាព្រះបាទជ័យវម៌្មនទី៧។[៤]

[៤]ដាំ ទិត្យាវ័ណ្យ ២០០៥: ៤១។

អត្ថបទដោយ៖ អ៊ូ គង្គា

លោក Vittorio យល់ដូចគ្នាដែរថា ចម្លាក់ត្រង់នេះ គឺកងទ័ពខ្មែរ និងចាម្បកំពុងប្រឈមមុខដាក់គ្នាស្រាប់តែផុសរូបព្រះនារាយណ៍គង់លើគ្រុឌចំកណ្តាលទី ដើម្បីកម្ចាចកម្លាំងទ័ពចាម្ប។[៥] ត្បិតកាយវិការរបស់កងទ័ពចាម្បបង្ហាញច្បាស់ណាស់ថា ពួកគេកំពុងឱនលំទោនវន្ទាចំពោះមុខព្រះនារាយណ៍ ខុសពីកងទ័ពខ្មែរដែលនៅពីក្រោយព្រះនារាយណ៍ហាក់ដូចកំពុងព្យាយាមវាយសម្រុកទៅមុខ។

នៅសម័យបុរាណ ការប្រដូចព្រះមហាក្សត្រទៅនឹងទេពសំខាន់ៗ ឬការយកទេពកថាមកបញ្ចូលក្នុងការលើកតម្កើងកិត្តិនាមព្រះមហាក្សត្រ គឺជាការពុំចម្លែកឡើយ។[៦] ដើម្បីពិនិត្យបន្ថែមរឿងនេះ សូមយើងក្រឡេកមើលតឹកតាងជាអក្សរវិញ។ សិលាចារឹកប្រាសាទព្រះខ័ន (K.908) ចារក្នុងសម័យកាលដូចគ្នានឹងចម្លាក់ខាងលើបានលើកតម្កើងព្រះបាទជ័យវម៌្មនទី៧ស្មើនឹងព្រះនារាយណ៍ថា «ពន្លឺថាមពលរបស់ព្រះអង្គ (ព្រះបាទជ័យវម៌្មនទី៧) ភ្លឺដូចអាវុធរបស់ព្រះនារាយណ៍បញ្ចេះទ័ពសត្រូវដូចភ្លើងអៅវ៉ដែលឆេះលឿនដូចភ្លើងឆេះព្រៃ។ ព្រះអង្គមានពន្លឺដូចព្រះចន្ទរះពេលយប់ ឯសត្រូវប្រៀបដូចជាផ្កាឈូកក្រពុំពេលយប់លំឱនកាយចំពោះព្រះភក្ត្រព្រះអង្គ»។[៧] ត្រង់នេះគេប្រៀបប្រដូចសត្រូវទៅនឹងផ្កាឈូក ត្បិតផ្កាឈូកតែងក្រពុំនៅពេលយប់ ដូចសត្រូវទាំងឡាយទ្រោមខ្លួនឱនលំទោនពេលឃើញព្រះអង្គ។ សិលាចារឹកនេះបន្តទៀតថា «គ្រាន់តែឃើញអាវុធដ៏គួរឱ្យខ្លាចរបស់ព្រះអង្គ សត្រូវទាំងប៉ុន្មានបន្ទន់ខ្លួនដូចពស់ទម្លាក់អាវុធចុះ ហើយបិទភ្នែក រីឯលំពែងដែលគេចោលទៅមុននោះក៏ធ្លាក់ជ្រុះអស់»។[៨] ដូចយើងដឹងស្រាប់ ក្នុងទេពកថាពស់ (ឬនាគ) តែងក្លាយជាចំណីរបស់គ្រុឌ។ យើងដឹងទូទៅថា គ្រុឌគឺជាយានជំនិះរបស់ព្រះនារាយណ៍ ហើយក៏តំណាងឱ្យព្រះនារាយណ៍ដែរ។ បំណងធំ គឺប្រៀបសត្រូវទៅនឹង

---

[៥] Vitorio 2005: 429។

[៦] សូមមើលឧទាហរណ៍ផ្សេងទៀតដែលសិក្សាដោយលោកគ្រូ ស៊ីយ៉ុន សុភារិទ្ធ ២០០៧។

[៧] Maxwell 2007: 22។

[៨] Maxwell 2007: 23។

ពស់ដែលតែងខ្ទបខ្ទាចគ្រុឌ ដូចសត្រូវទាំងនោះខ្ទបខ្ទាចតេជះព្រះអង្គដូច្នេះដែរ។ ចម្លាក់ខាងលើ សិល្បករចង់បង្ហាញថា ព្រះនារាយណ៍ និងព្រះមហាក្សត្រមានឫទ្ធិអំណាចដូចគ្នា ដែលធ្វើឱ្យសត្រូវខ្ទបខ្ទាចនៅចំពោះមុខព្រះអង្គ។ ឬនិយាយម្យ៉ាងទៀតថា ទ័ពព្រះអង្គមានព្រះនារាយណ៍ជាបង្អែក ទើបធ្វើឱ្យសង្គ្រាមតែងទទួលជោគជ័យ។

ជារួម ព្រះនារាយណ៍មានតួនាទីពិសេសក្នុងកិច្ចការសង្គ្រាមរបស់ក្សត្រ។ យើងឃើញទេពកថាច្រើនណាស់គឺ ព្រះនារាយណ៍តែងចូលអន្តរាគមន៍ ដើម្បីកម្ចាត់សភាវៈអាក្រក់ក្នុងន័យរក្សាសណ្ដាប់ធ្នាប់លោកទាំងមូល។ ម្យ៉ាងទៀត ការយកទេពកថាព្រះនារាយណ៍មកភ្ជាប់នឹងព្រះមហាក្សត្រក៏ឃើញមានមកដល់បច្ចុប្បន្នដែរ។ បើយើងពិនិត្យលំអិតលើនិមិត្តសញ្ញារបស់អង្គភាពនានានៃក្រសួងការពារជាតិ យើងនឹងឃើញតួអង្គសំខាន់ៗក្នុងទេពកថាអវតារនៃព្រះនារាយណ៍៕

អត្ថបទដោយ៖ អ៊ូ គង្គា

ឯកសារពិគ្រោះ

ស៊ីយ៉ុន សុភារិទ្ធ, ២០០៧, «ចម្លាក់ប្រលែងផ្ទូនៅអង្គរវត្ត និងនៅបាយ័ន្ត» *ព្រឹត្តិបត្តបុរាណវិទ្យា*, លេខ១, ទំ. ៣៩-៤៩

ដាំ ទិត្យាវ័ណ្ណ, ២០០៥, *ការកំណត់រឿងចម្លាក់នៅថែវខាងក្នុងប្រាសាទបាយ័ន្ត*, នក្លេបបទបុរាណវិទ្យា, ភ្នំពេញ

ហ៊ួន សារង, ២០១១, *ប្រៀបធៀបចម្លាក់ចម្បាំងនៅប្រាសាទបាយ័ន និងប្រាសាទបន្ទាយឆ្មារ*, នក្លេបបទបុរាណវិទ្យា, ភ្នំពេញ

អ៊ឹម សុខរិទ្ធី, ១៩៩៥, *ជីវភាពរបស់ប្រជាជនខ្មែរសម័យអង្គរ តាមរយៈក្បាច់ចម្លាក់ក្រឡោតទាបនៅប្រាសាទបាយ័ន*, នក្លេបបទបុរាណវិទ្យា, ភ្នំពេញ

Maxwell, Thomas, 2007, "The Stele Inscription of Preah Khan, Angkor: Text with Translation and Commentary", *UDAYA*, No.8, p.1-110

Vickery, Michael, 2005, "Champa Revised" *Asia Research Institute: Working Paper Series, No.37*, https://ari.nus.edu.sg/wp-content/uploads/2018/10/wps05_037.pdf (23/Mar/2023)

Vittorio, Roveda, 2005, *Images of the Gods*, Thailand: River Books

អត្ថបទដោយ៖ អ៊ូ គង្គា